**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ០៨៤៤/២៥ **ក.ប/ខ.ល**

# សារលិខិតអបអរសាទរ

**សូមគោរពជូន**

**សម្តេច ឥស្សរវិទេសបញ្ញា ហោ ណាំហុង**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ក្នុងឱកាសដ៏ប្រពៃថ្លៃថ្លាប្រកបដោយទឹកចិត្តសោមនស្សរីករាយ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំ និងភរិយា សូមសម្តែងនូវការអបអរសាទរជូនចំពោះ **ឯកឧត្តមកិត្តិបវិរក្សបណ្ឌិត** ក្នុងឱកាសត្រូវបាន **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ប្រោសព្រះរាជទានគោរមងារ ជា **សម្តេច ឥស្សរវិទេសបញ្ញា ហោ ណាំហុង**។

ការទទួលបានគោរមងារនេះ គឺពិតជាស័ក្តិសមបំផុតស្របទៅនឹងសមត្ថភាព ទេពកោសល្យ បទពិសោធ និងជាប្រមុខការទូតដ៏ឆ្នើម ដែលកន្លងមក **សម្តេច ឥស្សរវិទេសបញ្ញា** បានបូជានូវកម្លាំងកាយ ប្រាជ្ញាស្មារតី និងការធ្វើពលិកម្មសព្វបែបយ៉ាងដើម្បីបុព្វហេតុជាតិ មាតុភូមិ ការពារបូរណភាពទឹកដី អធិបតេយ្យភាព សុខសន្តិភាព សាមគ្គីភាព ស្ថិរភាពសង្គមបានល្អប្រសើរ ជាពិសេស បានលើកកម្ពស់វិស័យការទូតនៃព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជាមិត្ត និងមានកិច្ចសហប្រតិបត្តិការល្អលើឆាកអន្តរជាតិ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមគោរពជូនពរ **សម្តេច ឥស្សរវិទេសបញ្ញា** ទទួលបាននូវជោគជ័យថ្មីៗបន្ថែមទៀតក្នុងការបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តម ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោះព្រំ ប្រទានសព្វសាធុការពរ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរ ជូនដល់ **សម្តេច ឥស្សរវិទេសបញ្ញា** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេច ឥស្សរវិទេសបញ្ញា ហោ ណាំហុង** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ចន្ទ ១៤រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**